**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខៈ ០៧៥/១៥ ក.អ.ជ.ប្រក

ថ្ងៃ ចន្ទ ៣ កើត ខែ ពិសាខ ឆ្នាំ មមែ ព.ស.២៥៥៩

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មេសា គ.ស ២០១៥

# ប្រកាស

## ស្តីពី

## ការបង្កើតក្រុមការងារសម្របសម្រួល និងអនុវត្តកម្មវិធីកិច្ចសហប្រតិបត្តិការកាត់បន្ថយភាពក្រីក្រក្នុងក្របខណ្ឌហិរញ្ញប្បទានសហប្រតិបត្តិការជាមួយសាធារណរដ្ឋប្រជាមានិតចិន

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងលិខិតលេខ ២២៥៦ សហវ អថ ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## សម្រេច

**ប្រការ ១.-** បង្កើតក្រុមការងារសម្របសម្រួល និងអនុវត្តកម្មវិធីកិច្ចសហប្រតិបត្តិការកាត់បន្ថយភាពក្រីក្រក្នុងក្របខណ្ឌហិរញ្ញប្បទានសហប្រតិបត្តិការជាមួយសាធារណរដ្ឋប្រជាមានិតចិន ដែលមានសមាសភាពដូចខាងក្រោម÷

| | | |
|---|---|---|
| ១. លោកបណ្ឌិត **តាគ សុធា** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ | ប្រធាន |
| ២. លោក **អឿន ធារិទ្ធ** | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ | សមាជិក |
| ៣. លោក **ហឿង ជុនឡៀង** | ប្រធានការិយាល័យសហគ្រាសខ្នាតតូច | សមាជិក |

អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 724 193
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com

| | | |
|---|---|---|
| ៤. លោក **សែត សាម៉ុន** | អនុប្រធានការិយាល័យសហគ្រាសខ្នាតតូច | សមាជិក |
| ៥. លោក **ពេន ទិញ្ញាជិ** | មន្ត្រី | សមាជិក |
| ៦. លោក **គិត ផាណារ៉ូ** | មន្ត្រី | សមាជិក |
| ៧. កញ្ញា **ហ៊ុំ ចន្ទី** | មន្ត្រី | លេខាធិការ។ |

**ប្រការ** ២.-ក្រុមការងារសម្របសម្រួល និងអនុវត្តកម្មវិធីសម្រាប់កិច្ចសហប្រតិបត្តិការកាត់បន្ថយភាពក្រីក្រ ក្នុងក្របខណ្ឌហិរញ្ញប្បទានសហប្រតិបត្តិការជាមួយសាធារណរដ្ឋប្រជាមានិតចិន មានភារកិច្ចដូចខាងក្រោម÷

- សហប្រតិបត្តិការរៀបចំ និងអនុវត្តកម្មវិធីឱ្យស្របតាមកំណត់ហេតុកិច្ចប្រជុំស្តីពី កិច្ចសហប្រតិបត្តិការកាត់បន្ថយភាពក្រីក្រ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្មនៃសាធារណរដ្ឋប្រជាមានិតចិន
- សម្របសម្រួលអនុវត្តកម្មវិធីជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីឱ្យកម្មវិធីដំណើរការបានល្អ
- ត្រួតពិនិត្យ វាយតម្លៃ និងធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ
- ផ្សព្វផ្សាយលទ្ធផលការងាររបស់កម្មវិធីដែលសម្រេចបាន។

**ប្រការ** ៣.- នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស គ្រប់ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចមានក្នុងប្រការ ១ ត្រូវទទួលអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ជា សុផារ៉ា

<u>កន្លែងទទួល÷</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងពាណិជ្ជកម្មនៃសាធារណរដ្ឋប្រជាមានិតចិន

"ដើម្បីជូនជ្រាប"

- ដូចប្រការ ១ និងប្រការ ៣

"ដើម្បីអនុវត្ត"

- ឯកសារ-កាលប្បវត្តិ

Download